តុលាការជំបូងរបស់សហរដ្ឋអាមេរិក
សង្កាត់ លូវីស៊ាណាខាងកើត
(UNITED STATES DISTRICT COURT
EASTERN DISTRICT OF LOUISIANA)

| | | |
|---|---|---|
| យោងលើ៖ ការធ្លាយប្រេង ដោយសារការខួងយកប្រេង "តំបន់ទឹកជ្រៅ (Deepwater Horizon)" ឆ្នេរជាប់ឈូងសមុទ្រមិចស៊ីកូ ថ្ងៃទី20 ខែមេសា ឆ្នាំ 2010 | * | MDL No. 2179 |
| | * | ជំពូក៖ J |
| | * | ចៅក្រម BARBIER |
| ឯកសារនេះអនុវត្តចំពោះ៖ រាល់រឿងក្តីទាំងអស់ | * | ព្រះរាជអាជ្ញាឬចៅក្រមអម SHUSHAN |

<u>សាលក្រម</u>

[ការកែប្រែមាត្រានៃច្បាប់ ចំពោះសាលក្រមរបស់តុលាការលើកមុន ចុះថ្ងៃទី28 ខែធ្នូ ឆ្នាំ2011 ក្នុងការបង្កើតគណនី និងការតម្កល់ប្រាក់កក់ (ឯកសារលេខ 5022)]

នៅក្នុងសំបុត្រផ្ញើជូនតុលាការ ចុះថ្ងៃទី3 ខែមករា ឆ្នាំ2012 ស្ថាបនសម្របសម្រួលពាក្យបណ្តឹងសម្រាប់តំបន់ឆ្នេរជាប់ឈូងសមុទ្រ ("GCCF") បានសំដែងនូវការព្រួយបារម្ភមួយចំនួន ចំពោះសាលក្រមរបស់តុលាការ ចុះថ្ងៃទី28 ខែធ្នូ ឆ្នាំ2011 (ឯកសារលេខ 5022) ដែលបានបង្កើតគណនីប្រាក់តម្កល់មួយ "មូលនិធិរួម" និងតម្រូវឲ្យចុងចោទ និងភ្នាក់ងាររបស់ពួកគេកាត់ទុកនូវប្រាក់តម្កល់ 6% នៃប្រាក់ទូទាត់សំណង ដោយរួមទាំងប្រាក់សំណងដែលបានផ្តល់តាមរយៈស្ថាបន GCCF។ ឆ្លើយតបនឹងការព្រួយបារម្ភរបស់ស្ថាបន GCCF តុលាការ**សូមធ្វើការបញ្ជាក់ច្បាស់លាស់និងកែប្រែ**សាលក្រមលើកមុន អនុវត្តចំពោះតែការបង់ប្រាក់សណង ឬ ការទូទាត់ប្រាក់សំណងដោយស្ថាបន GCCF៖

1. ការកាត់ប្រាក់តម្កល់ 6% នឹងអនុវត្តចំពោះប្រាក់សំណងទាំងអស់ដែលរំពឹងទុកចំពោះ អ្នកប្តឹងទាមទារទាំងអស់ ដែលស្ថាបន GCCF មិនទាន់បានចេញសេចក្តីកំណត់ពីការបង់ ប្រាក់សំណង មកត្រឹមថ្ងៃទី30 ខែធ្នូ ឆ្នាំ2011។

2. ការកាត់ប្រាក់តម្កល់ 6% មិនអនុវត្តចំពោះការទូទាត់ប្រាក់សំណង (បណ្តោះអាសន្ន ឬ ចុងក្រោយ) ដែលបានធ្វើឡើងនៅថ្ងៃទី ឬ មុនថ្ងៃទី30 ខែធ្នូ ឆ្នាំ2011 ឬ ការកាត់ប្រាក់តម្កល់ មិនអនុវត្តចំពោះការទូទាត់ប្រាក់សំណងដែលផ្តល់ជូន ដែលមាននៅក្នុងសំបុត្របញ្ជាក់ ពីការបង់ប្រាក់សំណង ដែលស្ថាបន GCCF បានផ្ញើឲ្យលោកអ្នកនៅថ្ងៃទី ឬមុនថ្ងៃទី30 ខែធ្នូ ឆ្នាំ2011។

3. នៅពេលដែលស្ថាបន GCCF ធ្វើការបង់ប្រាក់សរុប (ឬ មួយចំណែក) ដោយអនុលោមតាម ការសុំតវ៉ាតាមផ្លូវច្បាប់ស្តីពីការអនុវត្តការសងបំណុល ឬ ដីកាតុលាការនៃបណ្តឹងរឹបអូស ទ្រព្យសម្បត្តិពីតតីយជន  ការកាត់ប្រាក់តម្កល់ 6% ត្រូវអនុវត្តចំពោះតែចំណែកជាសមាមាត្រ ទៅនឹងប្រាក់នៃការដោះស្រាយបណ្តឹង ដែលមិនមែនជាកម្មវត្ថុនៃ (ដែលមិនគិតពី) ប្រាក់ប្រដាប់ក្តី ឬ ប្រាក់នៃបណ្តឹងរឹបទ្រព្យពីតតីយជន (ឧទាហរណ៍៖ ចំនួន "ប្រាក់សំណងសុទ្ធ" ដែលសល់ពីការកាត់ប្រាក់ប្រដាប់ក្តី ឬទ្រព្យរឹបអូសពីតតីយជនចេញ)។

**បានចុះហត្ថលេខានៅ**ទីក្រុងញ៉ូអរលៀន នៃរដ្ឋល្វីស៊ីអាណា ថ្ងៃទី4 ខែមករា ឆ្នាំ2012

(ហត្ថលេខា)

ចៅក្រមនៃតុលាការជំបូងរបស់សហរដ្ឋអាមេរិក